# កំណត់ចំណាំសន្និសីទ



## ជំនួយមកពី ព្រះវិញ្ញាណបរិសុទ្ធ

ប្រធានអាវរិងបានមានប្រសាសន៍ថាលោកទទួលបានអារម្មណ៍នូវការលើកទឹកចិត្ត នៅពេលដែលលោកអានដំណើររឿងរបស់នីហ្វៃយកផ្ទាំងលង្ហិនពីឡាបាន់ ។នីហ្វៃ មិនបានដឹងច្បាស់ពីអ្វីដែលត្រូវធ្វើនោះទេប៉ុន្តែលោកត្រូវបានដឹកនាំដោយព្រះវិញ្ញាណ បរិសុទ្ធគ្រប់ពេលវេលា ។នៅពេលដែលព្រះអម្ចាស់សុំឲ្យយើងធ្វើអ្វីមួយដែលពិបាក នោះព្រះវិញ្ញាណបរិសុទ្ធនឹងជួយដល់យើងផងដែរ ។

ការណ៍នេះបង្រៀនខ្ញុំ ៖





## សូមចងចាំថា បងប្អូនគឺជានរណា

អែលឌើរស្ទីវែនសុនបានអញ្ជើញយើងឲ្យឈប់រាល់ពេលដែលយើងមើលខ្លួនយើង នៅក្នុងកញ្ចក់ ហើយនិយាយថា □ មើលខ្ញុំចុះ ! ខ្ញុំអស្ចារ្យណាស់ ! ខ្ញុំជាកូន របស់ព្រះ !ទ្រង់ស្គាល់ខ្ញុំ !ទ្រង់ស្រឡាញ់ខ្ញុំ ! □ការធ្វើបែបនេះនឹង ជួយយើងឲ្យចងចាំថាយើងពិតជានរណានិងរបៀបដែលព្រះ និងព្រះវិញ្ញាណបរិសុទ្ធអាចជួយយើងបាន ។

ការណ៍នេះបង្រៀនខ្ញុំ ៖





## សេចក្តីជំនឿលើ ព្រះយេស៊ូវគ្រីស្ទ

អែលឌើរខូស្បានចែកចាយដំណើររឿងអំពីពេលដែលព្រះយេស៊ូវគ្រីស្ទបានធ្វើ ឲ្យព្យុះស្ងប់ ។យើងទាំងអស់គ្នាមានព្យុះឬឧបសគ្គនានានៅក្នុងជីវិតដែលពិបាក ខ្លាំង ។ប៉ុន្តែយើងនឹងមិនត្រូវប្រឈមមុខនឹងរឿងទាំងនោះតែម្នាក់ឯងឡើយ ។ការ មានសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទនឹងផ្តល់អំណាចនិងសេចក្តីសុខសាន្តដល់ យើង នៅពេលយើងត្រូវប្រឈមមុខនឹងព្យុះណាមួយ ។

ការណ៍នេះបង្រៀនខ្ញុំ៖





## ដើរលើផ្លូវ ជាមួយនឹងទ្រង់

ប្រធានហ្វ្រីមែនបានប្រាប់ដំណើររឿងមួយអំពីពេលដែលគាត់ចង់ដើរលើផ្លូវពិសេស មួយទោះបីជាកជើងរបស់គាត់រងរបួសក៏ដោយ។គាត់មិនអាចដើរតាមផ្លូវនោះដោយ ខ្លួនឯងបានទេដូច្នេះអ្នកនាំផ្លូវម្នាក់បានជួយដល់គាត់ ។ដូចជាអ្នកនាំផ្លូវរបស់ប្រធាន ហ្វ្រីមែនដែរព្រះយេស៊ូវគ្រីស្ទនឹងជួយយើងជាមួយនឹងឧបសគ្គណាមួយនៅ ពេលយើងព្យាយាមរក្សាសេចក្តីសញ្ញារបស់យើង ។

ការណ៍នេះបង្រៀនខ្ញុំ ៖

